**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៧៤៥០ **អយក.ហវ**

ថ្ងៃសុក្រ ២កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

**ជម្រាបមក**
**ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្ដីការក្រសួង**

**កម្មវត្ថុ ៖**ករណីផ្ទេរឥណទានថវិកាចំនួន **១៣ ៥៩០ ៩៧២ ០០០រៀល** (ដប់បីប៊ីលាន ប្រាំរយកៅសិបលាន ប្រាំបួនរយចិតសិបពីរពាន់រៀលគត់) ក្នុងឆ្នាំ២០១៩ របស់អង្គភាពថវិកាថ្នាក់រដ្ឋបាលកណ្ដាល ស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ដោយបង្វែរចូលអង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ។

**យោង ៖** ចំណារឯកភាពរបស់ថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ លើកំណត់ហេតុប្រជុំពិភាក្សា ស្ដីពីស្ថានភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំ២០១៨ នៅក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា ៖ ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងកែទម្រង់វិស័យអប់រំយ៉ាងខ្លាំង ហើយស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងទិសដៅលើកកម្ពស់គុណភាពអប់រំ ជាពិសេសពាក់ព័ន្ធនឹងការអភិវឌ្ឍសាលាគរុកោសល្យ កម្មវិធីសិក្សា សម្ភារបរិក្ខារបច្ចេកទេស សម្ភាររៀននិងបង្រៀន ការជួសជុលកែលម្អអគាររដ្ឋបាល និងសាលារៀនសាធារណៈ ពីព្រោះវិស័យអប់រំជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិបច្ចុប្បន្ន។ ក្នុងន័យនេះ ក្រសួងស្នើសុំ ប្រធានអង្គភាព៖

**១-**ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ឥណទានថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា (ជំពូក គណនី និងអនុគណនី) ដែលនៅសល់ក្នុងឆ្នាំ២០១៨ ចុងក្រោយឲ្យបានត្រឹមត្រូវនិងច្បាស់លាស់

**២-**ឥណទាននៅសល់ក្នុងឆ្នាំ២០១៨ របស់អង្គភាព = (ឥណទានសល់សរុប) ដក (ឥណទានសល់ក្នុងជំពូក៦៤)

**៣-**ការផ្ទេរឥណទានថវិកាឆ្នាំ២០១៩ គឺស្មើនឹង៥០%នៃឥណទានថវិកាដែលនៅសល់ក្នុងឆ្នាំ២០១៨ (លក្ខខណ្ឌទី២ខាងលើ) របស់អង្គភាពសាមី ដោយបង្វែរចូលអង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ ដើម្បីបង្កលក្ខណៈងាយស្រួលឲ្យក្រសួងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ឥណទានថវិកាទាំងនេះ លើមុខសញ្ញាចំណាយជាអាទិភាពចាំបាច់និងបន្ទាន់មួយចំនួនក្នុងការអភិវឌ្ឍវិស័យអប់រំបច្ចុប្បន្ន ដូចជាការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ការពង្រឹងសមត្ថភាពមន្ត្រីអប់រំនិងជំនួយការអប្បមាទសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ការបើកថ្នាក់បណ្ឌិតអប់រំ ការធ្វើជាម្ចាស់ផ្ទះសម្រាប់រៀបចំ ‘ វេទិកាអាហារូបត្ថម្ភកុមារសកលប្រចាំឆ្នាំលើកទី២១ ’ នៅខេត្តសៀមរាប ។ល។

**៤-**រាល់ការផ្ទេរឥណទានថវិកាឆ្នាំ២០១៩ ជូនក្រសួង មិនចាំបាច់ផ្ដល់ដូចជំពូក គណនី និងអនុគណនី ដែលនៅសល់



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ក្នុងឆ្នាំ២០១៨ ទេ គឺទុកសិទ្ធិសម្រេចក្នុងការជ្រើសរើស ជំពូក គណនី និងអនុគណនីជូនអង្គភាពសាមី ហើយបញ្ជូនមកនាយកដ្ឋានហិរញ្ញវត្ថុ (ការិយាល័យជំនាញ) ឲ្យបានមុន**ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩** ជាកំហិត។ ដោយឡែកឥណទានថវិកា ដែលត្រូវផ្ទេរមិនទទួលនូវអនុគណនី៦០០៦១និង៦០០៦២ (អគ្គិសនីនិងទឹក) ជំពូក៦៤ ជំពូក៦៣ និងឥណទានក្នុងផែនការលទ្ធកម្ម ព្រមទាំងឥណទានថវិកាត្រូវបង្កកដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេសពាក់ព័ន្ធនឹងការស្នើសុំធានាចំណាយនានា។ ចំពោះអង្គភាព ត្រូវផ្ទេរឥណទានថវិកាក្នុងឆ្នាំ២០១៩ គឺអនុវត្តសម្រាប់អង្គភាពទាំងឡាយណាដែលមានអត្រាទូទាត់ថវិកាមិនបាន៩៥%នៃឥណទានកែតម្រូវ។ ទន្ទឹមនឹងនេះ ក៏មានគោលការណ៍ស្ម័គ្រចិត្តផងដែរ រួមមាន៖

**ឯកតា គិតជាពាន់រៀល**

| ល.រ | ឈ្មោះអង្គភាព | ឥណទាន សល់ឆ្នាំ២០១៨ | ឥណទាន សល់ជំពូក៦៤ | ឥណទាន ផ្ទេរឆ្នាំ២០១៩ | ស្ម័គ្រចិត្ត | សរុប |
|---|---|---|---|---|---|---|
| | **ផ្នែកអប់រំ** | **20,963,810** | **2,982,459** | **6,957,238** | **1,320,000** | **8,277,238** |
| | **កម្មវិធីទី ១** | **12,235,303** | **685,457** | **5,063,381** | **113,000** | **5,176,381** |
| 1 | នាយកដ្ឋានអប់រំកុមារតូច | 490,071 | - | 245,035 | - | 245,035 |
| 2 | នាយកដ្ឋានបឋមសិក្សា | 585,513 | - | 292,756 | - | 292,756 |
| 3 | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | 1,788,340 | 416,097 | 686,121 | - | 686,121 |
| 4 | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | 389,695 | 7,460 | 191,118 | - | 191,118 |
| 5 | នាយកដ្ឋានសុខភាពសិក្សា | 135,896 | - | 67,948 | - | 67,948 |
| 6 | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | 1,767,435 | - | 883,718 | - | 883,718 |
| 7 | នា.បណ្តុះបណ្តាល និងវិក្រឹតការ | 5,194,026 | 242,300 | 2,475,863 | - | 2,475,863 |
| 8 | នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា | 1,433,083 | 10,000 | - | 113,000 | 113,000 |
| 9 | នាយកដ្ឋានអប់រំពិសេស | 451,245 | 9,600 | 220,822 | - | 220,822 |
| | **កម្មវិធីទី ៥** | **8,728,507** | **2,297,002** | **1,893,857** | **1,207,000** | **3,100,857** |
| 10 | នាយកដ្ឋានផែនការ | 295,242 | - | - | 317,000 | 317,000 |
| 11 | នាយកដ្ឋានបុគ្គលិក | 2,176,430 | 1,898,651 | - | 30,000 | 30,000 |
| 12 | នាយកដ្ឋានហិរញ្ញវត្ថុ | 1,329,019 | 296,751 | - | - | - |
| 13 | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | 35,331 | 2,500 | 16,415 | - | 16,415 |
| 14 | នាយកដ្ឋានធានាគុណភាពអប់រំ | 31,697 | - | - | - | - |
| 15 | អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | 55,637 | 6,600 | 24,519 | - | 24,519 |
| 16 | នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន | 597,694 | 5,000 | 296,347 | - | 296,347 |
| 17 | នាយកដ្ឋាននីតិកម្ម | 99,552 | 7,000 | 46,276 | - | 46,276 |
| 18 | នាយកដ្ឋានសំណង់ | 642,669 | - | 321,335 | - | 321,335 |
| 19 | នាយកដ្ឋានសម្ភារនិងទ្រព្យសម្បត្តិរដ្ឋ | 423,505 | - | 211,753 | - | 211,753 |

| | | | | | | |
|---|---|---|---|---|---|---|
| 20 | នាយកដ្ឋានរដ្ឋបាល | 185,433 | 40,000 | 72,716 | - | 72,716 |
| 21 | នា.ទំ.ទំនងវប្បធម៌និងអាហារូបករណ៍ | 1,778,998 | 25,500 | 876,749 | - | 876,749 |
| 22 | នាយកដ្ឋានព័ត៌មានអប់រំ | 399,799 | 5,000 | - | 464,000 | 464,000 |
| 23 | នាយកដ្ឋានគោលនយោបាយ | 301,769 | 5,000 | - | 180,000 | 180,000 |
| 24 | នាយកដ្ឋានពិនិត្យនិងវាយតំលៃ | 320,239 | 5,000 | - | 216,000 | 216,000 |
| 25 | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន | 55,494 | - | 27,747 | - | 27,747 |
| | **ផ្នែកឧត្តមសិក្សា** | **6,712,339** | **981,713** | **2,010,632** | **1,478,602** | **3,489,234** |
| 26 | នាយកដ្ឋានឧត្តមសិក្សា | 262,431 | - | 131,216 | - | 131,216 |
| 27 | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | 614,082 | - | 307,041 | - | 307,041 |
| 28 | សាលកវិទ្យាល័យហេងសំរិនត្បូងឃ្មុំ | 250,585 | 28,800 | 110,893 | - | 110,893 |
| 29 | សាកលវិទ្យាល័យជាស៊ីម កំចាយមារ | 928,659 | 232,084 | 348,287 | - | 348,287 |
| 30 | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | 228,869 | 51,735 | - | 111,000 | 111,000 |
| 31 | វិទ្យាស្ថានជាតិអប់រំ | 1,885,390 | 512,328 | - | 1,327,602 | 1,327,602 |
| 32 | សាកលវិទ្យាល័យស្វាយរៀង | 157,593 | 6,520 | - | 40,000 | 40,000 |
| 33 | សាកលវិទ្យាល័យមានជ័យ | 988,850 | 6,400 | 491,225 | - | 491,225 |
| 34 | សាកលវិទ្យាល័យបាត់ដំបង | 601,161 | 29,300 | 285,930 | - | 285,930 |
| 35 | គណៈទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | 119,814 | - | 59,907 | - | 59,907 |
| 36 | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | 577,171 | 24,906 | 276,133 | - | 276,133 |
| 37 | សាកលវិទ្យាល័យក្រចេះ | 97,734 | 89,640 | - | - | - |
| | **ផ្នែកយុវជន និងកីឡា** | **4,897,164** | **127,636** | **1,824,500** | **-** | **1,824,500** |
| | **កម្មវិធីទី ៣** | **3,965,002** | **103,636** | **1,370,419** | **-** | **1,370,419** |
| 38 | នាយកដ្ឋានអប់រំកាយ និងកីឡា | 1,166,281 | 75,200 | 545,541 | - | 545,541 |
| 39 | នា.អប់រំកាយ និងកីឡាសិស្ស-និស្សិត | 1,090,681 | 17,838 | 536,422 | - | 536,422 |
| 40 | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | 582,111 | 5,198 | 288,456 | - | 288,456 |
| 41 | មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | 1,125,929 | 5,400 | - | - | - |
| | **កម្មវិធីទី ៤** | **932,162** | **24,000** | **454,081** | **-** | **454,081** |
| 42 | នាយកដ្ឋានយុវជន | 409,054 | 24,000 | 192,527 | - | 192,527 |
| 43 | នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលយុវជន | 370,681 | - | 185,340 | - | 185,340 |
| 44 | នាយកដ្ឋានសហប្រតិបត្តិការកាយរិទ្ធ | 152,427 | - | 76,214 | - | 76,214 |
| | **សរុបរួម** | **32,573,313** | **4,091,807** | **10,792,370** | **2,798,602** | **13,590,972** |

**៥**-នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកជាអ្នកសម្របសម្រួលលើការបូកសរុបនិងរៀបចំនីតិវិធីនិយ័តកម្មឥណទានថវិកាបស់អង្គភាពឲ្យទាន់ពេលវេលានិងត្រឹមត្រូវ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធាន** ត្រូវចូលរួមចាត់ចែងនិងសហការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់និងទាន់ពេលវេលា តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ចម្លងជូន៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
" ដើម្បីជ្រាបជាព័ត៌មាន "
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**